ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

លេខ.....៣១១៣.....បទ.៤ក.............

# ប្រកាស
## ស្តីពី
## ការប្រគល់ភារកិច្ច និងសិទ្ធិក្នុងការ ផ្តល់សេវាសាធារណៈមួយចំនួនរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូននិយ័តករទូរគមនាគមន៍កម្ពុជា

## រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការនៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួងនិងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា ២៩ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក

ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- អនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍កម្ពុជា
- យោងប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈ ដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

## សម្រេច

**ប្រការ ១.-**

ប្រគល់ភារកិច្ច និងសិទ្ធិឲ្យនិយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក.) ក្នុងការផ្តល់អាជ្ញាបណ្ណប្រេកង់វិទ្យុ, អាជ្ញាបណ្ណទូរគមនាគមន៍, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទ, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ (.kh) ព្រមទាំងចេញសារណាការនៃការងារ ជូសមុខឲ្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ២.-**

កម្រៃអាជ្ញាបណ្ណប្រេកង់វិទ្យុ, កម្រៃអាជ្ញាបណ្ណទូរគមនាគមន៍, កម្រៃលេខទូរសព្ទ (Telephone Numbering), និងកម្រៃសេវាគេហទំព័រ (.kh) ត្រូវប្រមូលនិងគ្រប់គ្រងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ស្របតាមខ្លឹមសារនៃប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត ដើម្បីបង់ចូលថវិកាជាតិស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងនៃឆ្នាំសារពើពន្ធនីមួយៗ របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

និយ័តករទូរគមនាគមន៍កម្ពុជា មានភារកិច្ចត្រួតពិនិត្យ គ្រប់គ្រងខាងបច្ចេកទេស និងរដ្ឋបាល លើការស្ថាបនា ការធ្វើប្រតិបត្តិការ ការផ្តល់ ការផ្ទេរ ការព្យួរ និងការដកហូតអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតពាក់ព័ន្ធនឹងការគ្រប់គ្រងមុខចំណូលដូចមានចែងក្នុងប្រការ១ខាងលើ។

**ប្រការ ៤.-**

រៀងរាល់ឆ្នាំសារពើពន្ធ (ឆ្នាំ “n”) និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំចេញអាជ្ញាបណ្ណប្រេកង់វិទ្យុថ្មីឬបន្ត, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទថ្មី, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ (.kh)ថ្មីឬបន្ត ព្រមទាំងសារណាការនៃការងារ សម្រាប់ឱ្យប្រតិបត្តិករទូរគមនាគមន៍ អង្គភាព ឬអ្នកប្រើប្រាស់ សម្រាប់ការគ្រប់គ្រងឆ្នាំបន្ទាប់ (ឆ្នាំ “n+1”)។

និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបញ្ជូនជាបណ្តើរៗចាប់ពីខែមករា រហូតដល់ដំណាច់ឆមាសទី១ នៃឆ្នាំសារពើពន្ធនីមួយៗ(ឆ្នាំ “n+1”)នូវបញ្ជីអាជ្ញាបណ្ណប្រេកង់វិទ្យុ, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទ, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ(.kh) ព្រមទាំងភ្ជាប់សារណាការនៃការងារជាច្បាប់ដើម និងអាជ្ញាបណ្ណប្រេកង់វិទ្យុ, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទ, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ (.kh), ជាច្បាប់ចម្លងដែលមានការបោះត្រាក្រហមសម្រាប់ការគ្រប់គ្រងឆ្នាំ “n+1” មកអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីចាត់ចែងឱ្យអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តបន្ត។

គ្រប់ការផ្តល់ថ្មី, ឬកែសម្រួល, ការផ្ទេរ, ការព្យួរ, និងការដកហូតអាជ្ញាបណ្ណទូរគមនាគមន៍ និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវបញ្ជូនអាជ្ញាបណ្ណ, លិខិតព្យួរ, និងលិខិតដកហូត ជាច្បាប់ចម្លង ដែលមានបោះត្រាក្រហមចំនួន០១ច្បាប់ មកអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីចាត់ចែងឲ្យអង្គភាពជំនាញពាក់ព័ន្ធរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍អនុវត្តបន្ត។

**ប្រការ ៥.-**

បន្ទាប់ពីទទួលបញ្ជីអាជ្ញាបណ្ណប្រេកង់វិទ្យុ, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទ, និងលិខិតអនុញ្ញាត

ប្រើប្រាស់គេហទំព័រ(.kh), ព្រមទាំងភ្ជាប់សារណាការនៃការងារជាច្បាប់ដើម និងអាជ្ញាបណ្ណហ្វ្រេកង់សវិទ្យុ, លិខិតអនុញ្ញាតប្រើប្រាស់លេខទូរសព្ទ, និងលិខិតអនុញ្ញាតប្រើប្រាស់គេហទំព័រ (.kh), ជាច្បាប់ចម្លង ដែលមានការបោះត្រាក្រហមពីនិយ័តករទូរគមនាគមន៍កម្ពុជា អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវចាត់បញ្ជូនឱ្យទៅនាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីបន្តការងារចេញវិក្កយបត្រ, កត់ត្រាតាមដានបំណុលត្រូវទារ, និងប្រមូលចំណូលបង់ចូលថវិកាជាតិ។ ជាមួយគ្នានេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ចំនួន០១ច្បាប់។

**ប្រការ ៦.-**

ក្នុងគោលបំណងសម្រួលដល់ប្រតិបត្តិករទូរគមនាគមន៍ អង្គភាព ឬអ្នកប្រើប្រាស់សេវា (តាមគោលការណ៍ច្រកចេញចូលតែមួយ) ក្នុងការស្នើសុំអាជ្ញាបណ្ណ ឬការអនុញ្ញាតនានា ការទទួលយកអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតនានា និយ័តករទូរគមនាគមន៍កម្ពុជា ត្រូវរៀបចំច្រកចេញចូលតែមួយស្របតាមប្រកាសរួមលេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

**ប្រការ ៧.-**

នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវរៀបចំរបាយការណ៍ចេញវិក្កយបត្រទាំងអស់ ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងចម្លងជូននិយ័តករទូរគមនាគមន៍កម្ពុជាចំនួន០១ច្បាប់។

រៀងរាល់ខែ, ត្រីមាស, ឆមាស, និងឆ្នាំ នាយកដ្ឋានផែនការ និងហិរញ្ញវត្ថុ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ត្រូវរៀបចំរបាយការណ៍ចំណូលពីកម្រៃអាជ្ញាបណ្ណហ្វ្រេកង់សវិទ្យុ កម្រៃអាជ្ញាបណ្ណទូរគមនាគមន៍កម្រៃលេខទូរសព្ទ និងកម្រៃសេវាគេហទំព័រ(.kh) ជូនឯកឧត្តមរដ្ឋមន្ត្រី និងចម្លងជូននិយ័តករទូរគមនាគមន៍កម្ពុជាចំនួន០១ច្បាប់។

**ប្រការ ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៩.-**

ប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា, អគ្គនាយករដ្ឋបាល, អគ្គាធិការ, អគ្គនាយកប្រៃសណីយ៍ និងទូរគមនាគមន៍, អគ្គនាយកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន, ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង, ប្រធាននាយកដ្ឋានផែនការនិងហិរញ្ញវត្ថុ, និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ អង្គារ ១៤រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី «ដើម្បីជូនជ្រាប»
- ដូចប្រការ៩ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ